# របាយការណ៍សង្ខេបនៃការនាំចេញអង្ករកម្ពុជា
# រយៈពេល៧ខែ ឆ្នាំ២០២០ និងខែកក្កដា ឆ្នាំ២០២០

# Cambodia's Rice Export Summary Report
# 7 months of 2020 and July 2020

CAMBODIA RICE FEDERATION

#2C, Street 120, Sangkat Phsar Tmey II, Khan Daun Penh, Phnom Penh, Cambodia

www.crf.org.kh    info@crf.org.kh    (855) 23 559 8999

## កម្ពុជានាំអង្ករចេញ ក្នុងរយៈពេល ៧ខែ បានចំនួនទឹកប្រាក់ជាង ២៨៥ លានដុល្លារសហរដ្ឋអាមេរិក

កម្ពុជាបាននាំចេញអង្ករចំនួន ៤២៦ ០៧៣ តោន ក្នុងរយៈពេល ៧ខែ នៅក្នុងឆ្នាំ២០២០ ដែលគិតជាកំណើន មានប្រមាណជា ៣៨.៣៣% ធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។ បើយើងប្រៀបធៀបកំណើនក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ (២០១៥-២០១៩) នោះ យើងឃើញថា កំណើននៃការនាំចេញរបស់យើង ក្នុងរយៈពេល៧ខែ ដូចគ្នាទៅនឹងឆ្នាំ២០២០នេះ មានភាពមិននឹងនរ ដែលមានមធ្យមភាគក្រោម១% ។

## Cambodia's Rice Export in 7 months of 2020 receiving more than USD 285 million

Cambodia export rice in the total amount of 426,073 tonnes in the 7 months' period of 2020, increased by 38.33% comparing to the same period in 2019. Comparing the growth of 7 months export period in the last 5 years (2015-2019) to the 7 months in 2020, the growth is unstable, with an average of less than 1%.

កំណើននៃការនាំចេញអង្ករសម្រាប់រយៈពេល៧ខែ នៅក្នុង៥ឆ្នាំចុងក្រោយ

Rice Export Trend for 7 months period in the last 5 years




គោលដៅទីផ្សារនាំចេញអង្ករកម្ពុជា ក្នុងរយៈពេល៧ខែ ឆ្នាំ២០២០

Cambodian Rice Market Desitnations in 7 months of 2020




ចំពោះកំណើននៃការនាំចេញអង្ករក្នុងរយៈពេល៧ខែ ឆ្នាំ២០២០ នេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារកត្តាមួយចំនួន ដូចជា ៖

១. តម្រូវការស្បៀងក្នុងកាលៈទេសៈនៃការរីករាលដាលជំងឺឆ្លងកូវីដ១៩នៅតាមបណ្តាប្រទេសនាំចូល

២. ការថយចុះនៃអត្រាពន្ធនាំចូលរបស់អង្ករកម្ពុជា ទៅកាន់ទីផ្សារសហគមន៍អឺរ៉ុបពី ១៧០អឺរ៉ូ មក ១៥០អឺរ៉ូ ក្នុងមួយតោន

៣. បរិមាណ និងសុពលភាពនៃកូតានាំចូលអង្ករកម្ពុជាទៅកាន់ទីផ្សារចិននៅមានចំនួនច្រើន រួមនឹងការធ្វើពិពិធកម្មទីផ្សារទៅកាន់ទីផ្សារហុងកុង អូស្ត្រាលី  រុស្ស៊ី និង ញូហ្សេឡេនជាដើម

៤.ការធ្វើពិពិធកម្មប្រភេទអង្ករ ពីអង្ករកិនធម្មតាទៅរកទីផ្សារអង្ករសម្រូប អង្ករសរីរាង្គ

៥. ការរក្សាបានកំណើនទីផ្សារនៅក្នុងប្រទេសម៉ាឡេស៊ី ប្រទេសប្រ៊ុយណេ និង ប្រទេសហ្គាប៊ុង ដែលប្រទេសទាំងបីនេះ កាន់កាប់ចំណែកទីផ្សារប្រទេសកម្ពុជា ជិត១៥%នៃបរិមាណអង្ករនាំចេញសរុប។

**សម្រាប់រយៈពេល ៧ខែនៃឆ្នាំ២០២០ នេះ ចំណូលដុលពីការនាំចេញអង្ករបានចំនួន ២៨៥.៨០លានដុល្លារសហរដ្ឋអាមេរិក។**

## ប្រភេទអង្ករនាំចេញ

ចាប់តាំងពីឆ្នាំ ២០១៦ យើងឃើញថាកំណើននៃការនាំចេញអង្ករក្រអូបមានកំណើនជាលំដាប់ រីឯអង្ករស និងអង្ករចំហុយមានទំនោរធ្លាក់ចុះជាគំហុកចាប់ពីឆ្នាំ២០១៨មក តែមានកំណើនវិញខ្លះ នៅឆ្នាំ២០២០ក្នុងដំណាក់កាលនៃជំងឺកូវីដ១៩ រីឯអង្ករសរីរាង្គនៅមានទំនោរកំណើនជាបណ្ដើរៗ។ សម្រាប់៧ខែក្នុងឆ្នាំ ២០២០នេះ អង្ករក្រអូបមានកំណើនប្រមាណជិត ៣២% ហើយអង្ករស មានកំណើនកើនជាង៨២% ហើយអង្ករសរីរាង្គមានកំណើនជាង ១៦% បើប្រៀបទៅរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៩។

អង្ករនាំចេញតាមប្រភេទ គិតពីឆ្នាំ២០១៦ ដល់ ខែកក្កដា ឆ្នាំ២០២០ Exported by rice variety from 2016 to July 2020




Rice Export in 7 months of 2020 is noticeably increased by some factors such as:

1. Food security demanded of Cambodian rice imported country during the pandemic of COVID-19
2. The decreased of tariff to EU from 170 Euros to 150 Euros per metric ton
3. The quantity & validity of Cambodian rice export’s Quota to China are still remaining, including the diversifying market to Hong Kong, Australia and New Zealand.
4. Diversifying varieties of rice from normal milled rice to brown rice, organic rice
5. Maintaining market growth in some specific markets such as Malaysia, Brunei and Gabon, in which these three market account for almost 15% of Cambodia's total rice exports.

**For the 7 months’ period of 2020, gross income from Cambodia’s rice export is USD 258.80 million.**

## Varieties of Rice Exported

Since 2016, we have seen a steady increase in exports of fragrant rice, while white rice and parboiled rice have been on a downward trend since 2018, with some rebounding in 2020 during COVID19, and on the other hand, organic rice, tends to grow gradually. For the seven months of 2020, fragrant rice is increased by nearly 32%, white rice increased by more than 82% and organic rice increased by more than 16% comparing to the same period in 2019.

ចំពោះការនាំចេញអង្ករប្រចាំខែកក្កដា ដែលជាទូទៅ គឺជាខែដែលការនាំចេញបានចំនួនតិចជាងគេនៃចំនួនខែទាំងអស់ប្រចាំឆ្នាំ គិតជាមធ្យមក្នុងខែកក្កដានេះ មានប្រហែលជា ២៦ ០០០ តោន ក្នុងមួយខែ  ដោយសារខែកក្កដា ជាខែចុងរដូវនៃស្តុកស្រូវស្រាល ដូចជាសែនក្រអូប សុមាលី និងពពួកស្រូវប្រកាន់រដូវ ដូចជាផ្ការំដួលផងដែរ។ សម្រាប់ខែកក្កដា ឆ្នាំ២០២០ នេះ កម្ពុជាបាននាំចេញអង្ករចំនួន ២៨ ៤១៣ តោន ដែលមានបរិមាណប្រហាក់ប្រហែលគ្នានឹងឆ្នាំ២០១៥ បាននាំចេញចំនួន ២៨ ៤៩២ តោន តែខុសគ្នាត្រង់ខែកក្កដា ឆ្នាំ២០២០ ភាគច្រើនជាអង្ករក្រអូប អង្ករសរីរាង្គ ខណៈដែលឆ្នាំ២០១៥ ភាគច្រើនជាអង្ករស ធម្មតា។

For rice exports in July, which are generally the lowest month of the year, averaged about 26,000 tonnes per month because July is the month at the end of the season of paddy rice's light stocks such as Sen Kraob, Somaly, and seasonal rice varieties such as Romduol. For July 2020, Cambodia exported 28,413 tons of rice, quite the same amount as in 2015, exported 28,492 tons, but different in July 2020, mostly export fragrant rice and organic rice, while in 2015 mostly were normal white rice.

ការនាំចេញក្នុងខែកក្កដា ឆ្នាំ២០២០ គិតជាទឹកប្រាក់បានចំនួន **២០.១២ លានដុល្លារសហរដ្ឋអាមេរិក។**

គោលដៅទីផ្សារនាំចេញអង្ករកម្ពុជា ក្នុងខែកក្កដា ឆ្នាំ២០២០

Cambodian Rice Market  Desitnations in July 2020

បរិមាណនាំចេញសរុប ៖ ២៨ ៤១៣ តោន

Total export: 28,413 Tonnes




The amount of gross income from exports in July 2020 is **USD 20.12 million.**


https://www.facebook.com/cambodiaricefederation/

www.crf.org.kh

https://twitter.com/RiceCrf

សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation

**សហព័ន្ធស្រូវអង្ករកម្ពុជា** (Cambodia Rice Federation)

ប្រធានក្រុមប្រឹក្សាភិបាល (Chairman) ៖ លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)
ប្រធានសហព័ន្ធ (President) ៖ លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)
អគ្គលេខាធិការ (Secretary General) ៖ លោក លន់ យ៉េង (Mr. Lun Yeng)

ដកស្រង់ និងវិភាគដោយ (Cited and Analysed by) ៖ លោក លន់ យ៉េង- អគ្គលេខាធិការ (Mr. Lun Yeng )
រចនាដោយ (Designed by) ៖ កញ្ញា សន ឆវីវតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង
(Ms. Sorn Chhorvyvatey - Communication Coordinator)




ប្រភពទិន្នន័យ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា    Source: Ministry of Agriculture Forestry and Fisheries, and General Department of Customs and Excise